**ព្រះរាជាណាចក្រកម្ពុជា**

**ក្រសួងអប់រំ យុវជន និង កីឡា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ : ០៦ អយក-សរណន

# សារាចរណែនាំ

## ស្តីពីការរៀបចំការគ្រប់គ្រង ដើម្បីធានានិរន្តរភាពការងារ

អនុវត្តតាមស្មារតីសេចក្តីជូនដំណឹងលេខ ៨១២ សជណ-សរ របស់សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់មន្ត្រីរាជការនៅថ្នាក់កណ្តាល និងខេត្ត ក្រុង ចំនួន ១៧៩៥ នាក់ ឱ្យចូលនិវត្តន៍។

ដូចនេះ ដើម្បីធានានិរន្តរភាពការងារនៅគ្រប់អង្គភាព និងគ្រឹះស្ថានសិក្សា ក្រសួងអប់រំ យុវជន និងកីឡា ណែនាំអនុវត្តដូចខាងក្រោម ÷

១. <u>ការងារគ្រប់គ្រង</u> :

មន្ត្រីគ្រប់គ្រងដែលកំពុងកាន់មុខតំណែង ត្រូវរៀបចំសមាសភាពគ្រប់គ្រងបន្ត។ ការជ្រើសរើសសមាសភាពនេះ ត្រូវផ្អែកលើគោលការណ៍របស់ក្រសួង អំពីសមត្ថភាពជំនាញ សមត្ថភាពគ្រប់គ្រង និងលក្ខណៈសម្បត្តិបុគ្គល ហើយត្រូវឆ្លងក្រុមប្រឹក្សាវិន័យ។ បន្ទាប់មកត្រូវរៀបចំសំណើតាមលំដាប់ឋានានុក្រមមកក្រសួង(នាយកដ្ឋានបុគ្គលិក) ដើម្បីពិនិត្យ និងសម្រេចពីថ្នាក់ដឹកនាំ។ ក្នុងរយៈពេលរង់ចាំការសម្រេចរបស់ក្រសួង មន្ទីរមានសិទ្ធិចេញលិខិតបង្គាប់ការឱ្យសាមីជន បំពេញមុខតំណែងគ្រប់គ្រង ដើម្បីធានានិរន្តរភាពការងារ លើកលែងឋានៈនាទីប្រធាន និងអនុប្រធានមន្ទីរ ដែលត្រូវស្នើចេញលិខិតឧទ្ទេសនាមចាត់តាំងជាបណ្តោះអាសន្នពីក្រសួង។ លិខិតបង្គាប់ការនេះ ត្រូវផ្ញើជូនក្រសួង (នាយកដ្ឋានបុគ្គលិក)។ អង្គភាព ឬមន្ទីរមិនត្រូវចេញប្រកាស ឬសេចក្តីសម្រេចអំពីការងារតែងតាំងមន្ត្រីគ្រប់គ្រងឡើយ។

ក្នុងករណីដែលពុំទាន់រកបានមុខសញ្ញា ដែលត្រូវប្រគល់ឱ្យកាន់មុខតំណែងគ្រប់គ្រងបន្តដូចខាងលើ គ្រប់អង្គភាព និងគ្រឹះស្ថានសិក្សា មានសិទ្ធិចេញលិខិតបង្គាប់ការចាត់តាំង " គណៈកម្មការគ្រប់គ្រងបណ្តោះអាសន្ន "។ គណៈកម្មការនេះមានសមាសភាពពី ៣ ទៅ ៥ នាក់ តាមករណីនីមួយៗ។ លិខិតបង្គាប់ការនេះ ត្រូវផ្ញើជូនឋានានុក្រមគ្រប់គ្រងថ្នាក់លើ ដើម្បីជារបាយការណ៍។ នៅខេត្ត ក្រុង មន្ទីរមានភារកិច្ចបញ្ជូនលិខិតបង្គាប់ការនេះមកក្រសួង (នាយកដ្ឋានបុគ្គលិក) ដើម្បីទុកជាឯកសារ។

រយៈពេលបំពេញការងាររបស់គណៈកម្មការគ្រប់គ្រងបណ្តោះអាសន្ន មានតម្លៃត្រឹម ៦ ខែ យ៉ាងយូរ ។ ចន្លោះពេលនេះ អគ្គនាយកដ្ឋាន ឬមន្ទីរ ត្រូវណែនាំ និងសហការជាមួយថ្នាក់ក្រោម ដែលមានបង្កើតគណៈកម្មការគ្រប់គ្រងបណ្តោះអាសន្ននេះ ដើម្បីជ្រើសរើសមុខសញ្ញាដែលត្រូវស្នើតែងតាំងជាស្ថាពរ ដូចមាននៅក្នុងវាក្យខ័ណ្ឌទី ១ ។

២. <u>ការងារបង្រៀន</u> :

ដើម្បីដោះស្រាយធានាការបង្រៀនសិស្ស (គ្រូកាន់ថ្នាក់) មន្ទីរអប់រំ យុវជន និងកីឡា មានភារកិច្ចជ្រើសរើសគ្រូកិច្ចសន្យាក្នុងចំណោមគ្រូបង្រៀនដែលចូលនិវត្តឆ្នាំ ១៩៩៩ និងមុននេះ គ្រូកិច្ចសន្យាចាស់តាមខ្លឹមសារលិខិតលេខ ១៩៧១ អយក-បល ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ និងលេខ ២៥១២ អយក-បល ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៩។ ការជ្រើសរើសគ្រូកិច្ចសន្យានេះ ត្រូវអនុវត្តបន្ទាប់ពីបានដោះស្រាយការប្រើប្រាស់គ្រូចេញថ្មីឆ្នាំ ១៩៩៩ ការបញ្ចេញបុគ្គលិករដ្ឋបាលឱ្យទៅបង្រៀន គ្រូបង្រៀនពីរថ្នាក់-ពីរពេល គ្រូបង្រៀនថ្នាក់គួបរួចហើយ ។ ឯការជ្រើសរើសអតីតសិស្សមកធ្វើជាគ្រូជាប់កិច្ចសន្យា ត្រូវទុកក្នុងជម្រើសចុងក្រោយ ដើម្បីបំពេញ ។

ក្នុងការជ្រើសរើសគ្រូកិច្ចសន្យានេះ ស្នើលោកប្រធានមន្ទីរធ្វើសំណើ និងស្ថិតិតម្រូវការ ហើយផ្ញើមកក្រសួងឱ្យទាន់ពេលវេលា និងគ្រោងថវិកាឱ្យហើយស្រេចនៅក្នុងឥណទានប្រចាំឆ្នាំ ។

ពេលទទួលបានសារាចរណែនាំនេះ គ្រប់ប្រធានអង្គភាពចំណុះទីស្តីការ និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង មានភារកិច្ចអនុវត្តឱ្យមានប្រសិទ្ធភាព និងរាយការណ៍មកក្រសួងនូវករណីដោយឡែកទាំងឡាយដែលកើតចេញពីការងារនេះ ។

ភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៩

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**តុល ឡោះ**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្ត ក្រុង
  "ដើម្បីជូនជ្រាប"
- គ្រប់អគ្គនាយកដ្ឋាន
- គ្រប់មន្ទីរ អយក ខេត្ត ក្រុង
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ ឯកសារ : ន.បល